វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA

# ឯកសារស្រាវជ្រាវសង្ខេប

## គណៈកម្មការទី១ នៃព្រឹទ្ធសភា

# ស្ថានភាពនៃការប្រកបរបរនេសាទសមុទ្រ និងការបង្កើតសហគមន៍នេសាទនៅតំបន់ឆ្នេរសមុទ្រ

ថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០១៧

អ្នកស្រាវជ្រាវ៖ លោកស្រី គុប ដាវី
លោក ឆន ម៉ូល
លោកស្រី គឹម កែវធីតា

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) គឺជាស្ថាប័នឯករាជ្យមួយដែលផ្តល់ការគាំទ្រដល់សភាកម្ពុជាតាមរយៈការផ្តល់នូវឯកសារស្រាវជ្រាវ ទៅតាមសំណើរបស់សមាជិក-សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា-ព្រឹទ្ធសភា ដែលមានការវិភាគទៅលើ បញ្ហាដែល កំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគតលើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយ សាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងការងារសភា និងការងារ មណ្ឌល ឬ ភូមិភាគរបស់សមាជិក-សមាជិការសភា ក៏ប៉ុន្តែ រាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាងឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់ វិទ្យាស្ថានសភាកម្ពុជា សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះមានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់តែជាឯកសារយោង ប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាអោយបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែលពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃគេហទំព័រនេះស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារនៅក្នុងគេហទំព័រនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថាន។

©រក្សាសិទ្ធិ ឆ្នាំ២០១៧ វិទ្យាស្ថានសភាកម្ពុជា(វ.ស.ក)។

# មាតិកា


១. សេចក្តីផ្តើម ..... 1

២. សហគមន៍នេសាទសមុទ្រ៖ សិទ្ធិ និងស្ថានភាពទូទៅ ..... 2

៣. បញ្ហាប្រឈមដែលសហគមន៍នេសាទកំពុងជួបប្រទះ ..... 5

៤. គោលនយោបាយដែលមានស្រាប់ទាក់ទងនឹងសហគមន៍នេសាទសមុទ្រ ..... 7

៥. ការដោះស្រាយនូវបញ្ហាប្រឈមខាងលើ ..... 9

៦. សេចក្តីសន្និដ្ឋាន ..... 10

## ១. សេចក្តីផ្តើម

វិស័យជលផលនៅក្នុងប្រទេសកម្ពុជាគឺជាវិស័យមួយដែលមានសារៈសំខាន់ ដោយផ្តល់ប្រូតេអ៊ីនជាតិសាច់ប្រមាណ៨០%សម្រាប់ប្រជាជន ជាពិសេសសំខាន់សម្រាប់សន្តិសុខស្បៀង និងចំណូលសម្រាប់ប្រជាជនក្រីក្រ។[1] ទោះបីជាទិន្នផលជលផលសមុទ្រនៅក្នុងប្រទេសកម្ពុជាមានចំនួនតិចតួច(ប្រហែល ២០%នៃទិន្នផលជលផលសរុប [១២០៥០០ តោន ក្នុងមួយឆ្នាំ]) ធៀបនឹងទិន្នផលជលផលទឹកសាបក៏ដោយ ក៏ទិន្នផលនេះផ្តល់ជាប្រភពចំណូលចិញ្ចឹមជីវិតដល់ប្រជាជននៅតំបន់ឆ្នេចំនួនបួនខេត្ត ដូចជា ខេត្តព្រះសីហនុ កោះកុង កែប និងកំពត។[2]នៅក្នុងខេត្តកែបប្រជាជនបានប្រកបរបរនេសាទសមុទ្រសរុបចំនួន ៤,៣០% នៃចំនួនប្រជាជនសរុប (២០១៦) ៥,១០% នៅក្នុងខេត្តព្រះសីហនុ(២០១៥) ១,៤% នៅក្នុងខេត្តកំពត (២០១៤) និង ១៧% នៅក្នុងខេត្តកោះកុង(២០១៤)។ ការអភិវឌ្ឍនាពេលបច្ចុប្បន្នមានដូចជាការពង្រីកកំពង់ផែឆ្នេសមុទ្រនៅក្នុងក្រុងព្រះសីហនុ ការអភិវឌ្ឍតំបន់ឧស្សាហកម្មដែលឲ្យឈ្មោះថា«តំបន់ឧស្សាហកម្មស្ទឹងហាវក្រុងព្រះសីហនុ» ដែលរួមបញ្ចូលផលិតកម្មឧស្ម័នធម្មជាតិ ការកែច្នៃចំណីអាហារតាមរយៈនេសាទត្រីពីមូលដ្ឋាន ការកែច្នៃឈើ ជាដើម អាចផ្តល់ផលប្រយោជន៍មួយចំនួនដល់សហគមន៍ប្រជានេសាទ។[3] ទោះបីជាយ៉ាងណាក៏ដោយ ការអភិវឌ្ឍទាំងនេះអាចបង្កឲ្យមានជម្លោះក្នុងវិស័យជលផល និងប៉ះពាល់ដល់បរិស្ថានសមុទ្រ។

តាមរយៈការធ្វើកំណែទម្រង់វិស័យជលផលនៅក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ២០០០មក សហគមន៍នេសាទត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រង ការពារ និងអភិវឌ្ឍន៍ធនធានជលផលធម្មជាតិឲ្យមានចីរភាព។[4] ជាលទ្ធផលនៃការធ្វើកំណែទម្រង់សហគមន៍នេសាទចំនួន៥១៧ ត្រូវបានបង្កើតឡើងនៅទូទាំងប្រទេសសម្រាប់របរនេសាទខ្នាតតូច។[2]

ការសិក្សាបច្ចុប្បន្នមួយដែលមានចំណងជើងថា «ការរៀបចំសហគមន៍នេសាទនៅកម្ពុជា(Community Fisheries Organizations of Cambodia)» ដែលបានធ្វើដោយអង្គការស្បៀងអាហារនិងកសិកម្មនៃសហប្រជាជាតិ(FAO) និងរដ្ឋបាលជលផល(FiA) នៅក្នុងឆ្នាំ២០១២ បានលើកឡើងពីបទពិសោធន៍របស់សហគមន៍នេសាទ និងសេចក្តីប្រាថ្នារបស់ពួកគេនាពេលអនាគត។ ការសិក្សាបានពិនិត្យមើលលើសហគមន៍នេសាទចំនួន ៦០ រួមមានសហគមន៍នេសាទសមុទ្រចំនួន ១៥។ ការសិក្សានេះបានរកឃើញថាការធ្វើកំណែទម្រង់វិស័យជលផលបច្ចុប្បន្នគឺជាភាពជោគជ័យមួយទាក់ទងនឹងការលើកកម្ពស់ជីវភាពរស់នៅ និងការផ្តល់នូវប្រភពនៃការរកស៊ីចិញ្ចឹមជីវិត ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ សហគមន៍នេសាទនៅតែជួបប្រទះបញ្ហាប្រឈមមួយចំនួនទាក់ទងនឹងជីវភាពរស់នៅ និងការគ្រប់គ្រងសហគមន៍នេសាទរបស់ពួកគេ។ [4]

ឯកសារស្រាវជ្រាវសង្ខេបនេះនឹងពិនិត្យមើលលើបញ្ហាប្រឈមដែលសហគមន៍នេសាទកំពុងជួបប្រទះ និងសិទ្ធិក្នុងការបង្កើតសហគមន៍នេសាទ ព្រមជាមួយនឹងគោលនយោបាយ និងក្របខណ្ឌបញ្ញត្តិពាក់ព័ន្ធនានា ដែល រដ្ឋាភិបាលកំពុងអនុវត្តដើម្បីជួយដល់ការដោះស្រាយបញ្ហាប្រឈមរបស់សហគមន៍នេសាទ។ ជាពិសេស ឯកសារស្រាវជ្រាវសង្ខេបនេះនឹងឆ្លើយតបទៅនឹងសំនួរមួយចំនួនដូចខាងក្រោម៖

១. តើការអភិវឌ្ឍបច្ចុប្បន្នមានផលប៉ះពាល់អ្វីខ្លះដល់សិទ្ធិ និងការអភិវឌ្ឍសហគមន៍នេសាទនៅតំបន់ឆ្នេរនៃខេត្តទាំងបួន?
២. តើមានបញ្ហាប្រឈមអ្វីខ្លះដែលសហគមន៍នេសាទកំពុងជួបប្រទះ ?
៣. តើមានយន្តការផ្លូវច្បាប់ និងគោលនយោបាយ អ្វីខ្លះដែលរាជរដ្ឋាភិបាលបាននឹងកំពុងអនុវត្ត ដើម្បីជួយ ដោះស្រាយនូវបញ្ហាប្រឈមរបស់សហគមន៍នេសាទ?
៤. តើអាជ្ញាធមូលដ្ឋានមានផែនការអ្វីខ្លះដើម្បីជួយដល់ការអភិវឌ្ឍសហគមន៍នេសាទនៅតំបន់ឆ្នេរ?

## ២. សហគមន៍នេសាទសមុទ្រ៖ សិទ្ធិ និងស្ថានភាពទូទៅ

### *សិទ្ធិក្នុងការបង្កើតសហគមន៍នេសាទ និងសិទ្ធិប្រើប្រាស់ធនធានជលផល*

យោងតាមព្រះរាជក្រឹត្យស្តីពីការបង្កើតសហគមន៍នេសាទ ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិរួមគ្នាបង្កើតសហគមន៍នេសាទនៅតាមមូលដ្ឋានរបស់ខ្លួន និងមានគំនិតផ្តួចផ្តើមបង្កើនជីវភាពរបស់ខ្លួន តាមរយៈការប្រើប្រាស់ធនធានប្រកបដោយចីរភាព។[3] រហូតមកដល់ពេលនេះ មានសហគមន៍នេសាទសមុទ្រចំនួន ៤០ ត្រូវបានបង្កើតឡើង ដែលគ្របដណ្តប់ ៨១ភូមិ (សហគមន៍នេសាទសមុទ្រចំនួន ១០ នៅខេត្តកោះកុង ១៦ នៅខេត្តព្រះសីហនុ និង ១៤ នៅខេត្តកំពត)។ សហគមន៍នេសាទសមុទ្រនីមួយៗ គ្រប់គ្រងដែននេសាទរបស់ខ្លួន នៅក្រោមកិច្ចព្រមព្រៀងនេសាទសហគមន៍ បោះឆ្នោតជ្រើសរើសប្រធាន ត្រូវមានគណៈកម្មការគ្រប់គ្រង រៀបចំបទបញ្ជាផ្ទៃក្នុង (ការប្រើប្រាស់ធនធាន) និងផែនការគ្រប់គ្រង។

សហគមន៍នេសាទសមុទ្រមានសិទ្ធិប្រើប្រាស់ធនធានជលផលប្រពៃណីរបស់សហគមន៍មូលដ្ឋាន។ ពាក្យថា «ការប្រើប្រាស់លក្ខណៈប្រពៃណី» គឺសំដៅដល់ការប្រើប្រាស់ឧបករណ៍នេសាទជាលក្ខណៈគ្រួសារ (សំណាញ់ សន្ទូច និងអង្គប់) នៅតាមឆ្នេរ (ដែលលាតសន្ធឹងពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតរហូតដល់ខ្សែបន្ទាត់ដែលមានជម្រៅទឹកម្ភៃ ម៉ែត្រ។[5] ដើម្បីធានាការប្រើប្រាស់ធនធានប្រកបដោយចិរភាព សហគមន៍នេសាទត្រូវធ្វើផែនការ និងសកម្មភាពអភិរក្សនៅក្នុងដែននេសាទរបស់ខ្លួន ដូចជា ការការពារ ការដាំព្រៃកោងកាង និងការបង្កើតក្រុមយាមល្បាតដើម្បីឃ្លាំមើលការនេសាទខុសច្បាប់។[6, 7] សហគមន៍នេសាទទទួលការគាំទ្រពីរដ្ឋបាលជលផល និងអង្គការក្រៅរដ្ឋាភិបាលផ្សេងៗដែលកំពុងធ្វើការនៅក្នុងវិស័យជលផល។[5]

សហគមន៍នេសាទមានសកម្មភាពជាច្រើនផ្សេងទៀតដើម្បីជួយអភិវឌ្ឍ និងជំរុញកម្រិតជីវភាពផ្សេងៗទៀត។ សកម្មភាពទាំងនោះអាចរួមមាន សកម្មភាពកសិកម្មនានា ក្រុមសន្សំប្រាក់[i] និងសកម្មភាពនានាទាក់ទងនឹងអេកូទេសចណ៍ ។ល។[4, 5]

---

[i] គំនិតផ្តួចផ្តើមនៃការបង្កើតក្រុមសន្សំ គឺជាគម្រោងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនានិទាឃរដូវ ដែលផ្តល់មូលនិធិដោយប្រទេសស៊ុយអែត និងអូស្ត្រាលី។ បើសិនជាអ្នកនេសាទទៅខ្ចីប្រាក់ពីខាងក្រៅ សាច់ប្រាក់ហ្នឹងហូរចេញពីភូមិតាមរយៈការសងបំណុល និងការប្រាក់។ ប៉ុន្តែផ្ទុយទៅវិញ ក្រុមសន្សំនេះ ធ្វើឲ្យសាច់ប្រាក់វិលចុះឡើងតែនៅក្នុងភូមិ/សហគមន៍របស់ពួកគេ។

គោលបំណងមួយនៃការបង្កើតសហគមន៍នេសាទគឺ ធានាឲ្យការគ្រប់គ្រងធនធានជលផលនៅថ្នាក់មូលដ្ឋានមានចិរភាព និងការបែងចែកធនធានដល់ប្រជាពលរដ្ឋដោយសមធម៌ ។[8] គួរកត់សម្គាល់ផងដែរថាយោងតាមច្បាប់ស្តីពីជលផល ពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិធ្វើការនេសាទគ្រប់ពេលវេលា និងនៅគ្រប់ទីកន្លែងក្នុងដែនសមុទ្រខ្មែរ។ នេះមានន័យថា ប្រជាពលរដ្ឋដែលមិនមែនជាសមាជិកសហគមន៍នេសាទណាមួយ អាចធ្វើនេសាទបានគ្រប់កន្លែង ទោះជាក្នុងដែននេសាទរបស់សហគមន៍នេសាទដែលខ្លួនមិនមែនជាសមាជិកក៏ដោយ ដ៏រាបណា ជននោះគោរពបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទនោះ ។[5, 9]

## *ស្ថានភាពបច្ចុប្បន្ន*

**តារាងទី១៖ មុខរបរ[4]**

| **មុខរបរ** | **សហគមន៍នេសាទសមុទ្រ(%)** |
|---|---|
| នេសាទ | ៥០ |
| កសិករ | ១២ |
| នេសាទ និងកសិករ | ២៨ |
| អ្នកលក់ត្រី | ២ |
| កែច្នៃត្រី | ២ |
| មុខរបរផ្សេងៗ | ៥ |
| សរុប | ១០០ |

សមាជិកសហគមន៍នេសាទភាគច្រើនមានមុខរបរទាក់ទងនឹងការនេសាទ។ តារាងទី១ បានដកស្រង់ចេញពីការសិក្សាស្ទង់មតិរបស់សហគមន៍នេសាទសមុទ្រចំនួន១៥។ ការសិក្សានេះបានរកឃើញថាមានប្រជាជនចំនួនប្រមាណ៥០ភាគរយ ប្រកបរបរជាអ្នកនេសាទ ហើយប្រហែលជាមួយភាគបួនប៉ុណ្ណោះមានមុខរបរជាអ្នកនេសាទផង និងកសិករផង។ ចំណែកឯអ្នកផ្សេងទៀត ក៏នៅតែមានមុខរបរពាក់ព័ន្ធនឹងជលផលផងដែរ ។[4]

## *តំបន់ការពារជលផលសមុទ្រ*

ដើម្បីឆ្លើយតបទៅនឹងសម្ពាធសេដ្ឋកិច្ច និងប្រជាសាស្ត្រទៅលើធនធាននៅតំបន់ឆ្នេរសមុទ្រ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតតំបន់ការពារដោយផ្អែកលើព្រះរាជក្រឹត្យឆ្នាំ១៩៩៣ ។[10, p.22] ក្នុងចំណោមតំបន់ការពារចំនួន ២៣ នៅប្រទេសកម្ពុជា មានតំបន់ការពារសមុទ្រ និងតំបន់ឆ្នេរចំនួន ៦កន្លែង[ii] ដែលគ្របដណ្តប់លើផ្ទៃដីចំនួន៣៨៨.៧០០ ហិកតា ។[10, pp.14-22] លើសពីនេះ មានតំបន់ការពារចំនួន៣កន្លែងទៀត ដែលផ្នែកខ្លះមានទីតាំងស្ថិតនៅតំបន់ឆ្នេរផង និងនៅតំបន់កណ្តាលជួរភ្នំក្រវាញផង។[10, p.22] នៅក្នុងឆ្នាំ២០១៦ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្កើតតំបន់ការពារជលផលសមុទ្រ (Marine Protected Area) ច្បាស់លាស់មួយនៅជុំវិញកោះរុង និងកោះរុងសន្លឹម ដែលគ្របដណ្តប់លើផ្ទៃដីប្រមាណជា ៤០៥ គីឡូម៉ែត្រការ៉េ។[11]

---

[ii] តំបន់ការពារទាំងប្រាំមួយរួមមាន៖ ១) ឧទ្យានជាតិកែប ២) ឧទ្យានជាតិបូកគោ ៣)ឧទ្យានជាតិរាម ៤) ឧទ្យានជាតិបុទមសាគរ ៥)ជម្រកសត្វព្រៃពាមក្រសោប និង៦)កន្លែងប្រើជាច្រើននៅតំបន់ដូងបេង

គោលបំណងចម្បងនៃការកំណត់តំបន់ការពារសមុទ្រ [iii] គឺដើម្បីធានាថាធនធានជលផលត្រូវបានគ្រប់គ្រងប្រកបដោយចីរភាព ក៏ដូចជាការជំរុញវិស័យទេសចរណ៍ ការកាត់បន្ថយភាពក្រីក្រ និងការថែរក្សាជីវចម្រុះផងដែរ។[12] តំបន់ការពារជលផលសមុទ្រនេះ អាចប្រើប្រាស់សម្រាប់អភិរក្សផ្នែកជាច្រើននៃអេកូឡូស៊ីសមុទ្រ រួមទាំងអភិរក្សផលស្តុកត្រីដែលត្រូវបានជួញដូរដោយអាជីវកម្មនេសាទផងដែរ។[13, p.1]

## ក្រាហ្វិកទី១៖ ទីតាំងសហគមន៍នេសាទសមុទ្រ



សហគមន៍នេសាទ ក៏ជាផ្នែកមួយនៅក្នុងគោលនយោបាយអភិវឌ្ឍន៍ជាតិផងដែរ ហេតុដូច្នេះហើយទើបសហគមន៍នេសាទមិនត្រឹមតែទទួលបានអត្ថប្រយោជន៍ពីគោលនយោបាយអភិវឌ្ឍន៍ និងការងារអភិវឌ្ឍន៍ទាក់ទងនឹងវិស័យជលផលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទទួលបានប្រយោជន៍ពីគោលនយោបាយ និងការងារអភិវឌ្ឍផ្សេងៗទៀត ដូចជាកំណើនសេដ្ឋកិច្ចទូទៅ ការអភិវឌ្ឍកសិកម្ម លទ្ធភាពទទួលបានឱកាសការងារ ការអភិវឌ្ឍធនធានមនុស្ស និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការជាដើម។[14]

ការអភិវឌ្ឍនាពេលបច្ចុប្បន្នផ្សេងទៀត អាចមានផលប៉ះពាល់ដល់ប្រយោជន៍សហគមន៍នេសាទសមុទ្រ រួមមានការពង្រីកកំពង់ផែនៅតំបន់ឆ្នេរសមុទ្រនៃក្រុងព្រះសីហនុ តំបន់អភិវឌ្ឍន៍ឧស្សាហកម្មដែលគេហៅថា «តំបន់ឧស្សាហកម្មស្ទឹងហាវក្រុងព្រះសីហនុ» ដែលរួមមានការផលិតឧស្ម័នធម្មជាតិ ការកែច្នៃម្ហូបអាហារដែលប្រើពីផលចាប់ជលផលថ្នាក់មូលដ្ឋាន និងការកែច្នៃឈើជាដើម។ល។ ទោះបីជាយ៉ាងណាក៏ដោយ ការអភិវឌ្ឍនេះអាចបង្កឲ្យមានជម្លោះក្នុងវិស័យជលផល និងផ្តល់ផលប៉ះពាល់ដល់បរិស្ថានសមុទ្រផងដែរ។[3]

តំបន់ឆ្នេរ បានដើរតួដ៏សំខាន់ក្នុងយុទ្ធសាស្ត្រទេសចរណ៍ដែលក្លាយជាប្រភពចំណូលដ៏សំខាន់មួយរបស់រដ្ឋាភិបាល។ ដោយសារលក្ខណៈប្រព័ន្ធអេកូឡូស៊ីរបស់ខ្លួន តំបន់ឆ្នេរត្រូវចាត់ទុកជាតំបន់ដែលមានសក្តានុពលខ្ពស់ក្នុងការទាក់ទាញភ្ញៀវទេសចរណ៍ ក៏ដូចជាការគាំទ្រដល់សកម្មភាពអភិរក្សជាច្រើន ដូចជាការការពារ និងការដាំព្រៃកោងកាងឡើងវិញជាដើម។[4, p.87] នៅក្នុងឆ្នាំ២០១៦ តំបន់ឆ្នេរ ទទួលបានភ្ញៀវទេសចរណ៍អន្តរជាតិចំនួន ៦៤៣.២៨៩នាក់ បើប្រៀបធៀបនឹងភ្ញៀវទេសចរណ៍ជាតិចំនួន ៥.៧២១.៣៥០ នាក់។ [15] រដ្ឋាភិបាលមានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍តំបន់ឆ្នេរ ក្នុងគោលបំណងដើម្បីទាក់ទាញអ្នក វិនិយោគទូទាំងពិភពលោកមកអភិវឌ្ឍន៍វិស័យទេសចរណ៍ ដែលអាចផ្តល់ជាប្រភពចំណូល

[iii] តំបន់គ្រប់គ្រងជលផលសមុទ្រ

បន្ថែមទៀតដល់ រដ្ឋាភិបាល និងអាចផ្តល់ឱកាសការងារសម្រាប់ប្រជាជនក្នុងតំបន់នោះផងដែរ។

ការកើនឡើងភ្ញៀវទេសចរមកដល់ប្រទេសកម្ពុជា និងតំបន់ឆ្នេរ បានជំរុញឲ្យមានការកើនឡើងនូវតម្រូវការសម្រាប់ចំណីអាហារពីសំណាក់ភ្ញៀវទេសចរទាំងនោះផងដែរ។[3, p.26] ទាំងនេះបណ្តាលឲ្យមានការកើននូវតម្លៃត្រីសមុទ្រនៅលើទីផ្សារក្នុងស្រុក នៅប្រទេសកម្ពុជា។

## ៣. បញ្ហាប្រឈមដែលសហគមន៍នេសាទកំពុងជួបប្រទះ

សកម្មភាពនេសាទខុសច្បាប់នៅតែជាបញ្ហាប្រឈមរបស់សហគមន៍នេសាទសមុទ្រ។[4] ការនេសាទខុស-ច្បាប់មានពីរប្រភេទ៖ (១) ការនេសាទខុសច្បាប់ ធ្វើឡើងតាមរយៈបុគ្គលដោយសារភាពក្រីក្រ និង (២) ការនេសាទ និងការបំផ្លិចបំផ្លាញខុសច្បាប់ធ្វើឡើងក្នុងគោលបំណងពាណិជ្ជកម្ម។[4] ក៏មានសកម្មភាពនេសាទខុសច្បាប់ដោយនាវានេសាទពីប្រទេសដ៏ទៃទៀតផងដែរ។

**តារាងទី២៖ សកម្មភាពនេសាទខុសច្បាប់**

| ការគំរាមកំហែងទឹកសមុទ្រ | ភាគរយ |
|---|---|
| ការនេសាទដោយប្រើមង | ៧៣% |
| ការអូសអួនដោយប្រើទូកធំៗ | ៣៧% |
| ការនេសាទខុសច្បាប់ដោយកប៉ាល់មកពីប្រទេសដ៏ទៃ | ១៧% |
| ការបំពុលទឹកសមុទ្រ | ១០% |

*ប្រភព៖ ការរៀបចំសហគមន៍នេសាទប្រទេសកម្ពុជា[4]*

បទល្មើសនេសាទ គឺជាបទល្មើសព្រហ្មទណ្ឌ ហើយមន្រ្តីរដ្ឋបាលជលផលដែលជាមន្ត្រីនគរបាលជលផល មានតួនាទីស៊ើបអង្កេតបទល្មើសជលផល និងដាក់ពាក្យបណ្តឹង(កសាងសំនុំរឿង)។ អាជ្ញាធរមូលដ្ឋានសហការជាមួយរដ្ឋបាលជលផល និងផ្តល់ជាកម្លាំងដើម្បីស៊ើបអង្កេត និងរារាំងបទល្មើសជលផល។ [5] សហគមន៍នេសាទសហការជាមួយរដ្ឋបាលជលផលក្នុងការដោះស្រាយបទល្មើសជលផល ក្នុងករណីចំបាច់ពួកគេ សហការជាមួយអាជ្ញាធរមូលដ្ឋានចុះចាប់ខ្លួនជនល្មើស ព្រមទាំងរឹបអូសយកភស្តុតាងសម្រាប់មន្ត្រីរដ្ឋបាលជលផល។[9]

ក្រុមល្បាតនៅតាមសហគមន៍នេសាទនីមួយៗ ត្រូវបានបង្កើតឡើងដើម្បីបង្ការទប់ស្កាត់ដល់សកម្មភាពនេសាទខុសច្បាប់នានា។[6, 7] ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ សហគមន៍នេសាទអះអាងថាពួកគេមិនមានធនធានគ្រប់គ្រាន់ ឬសិទ្ធិអំណាច ដើម្បីចាប់ជនល្មើសនោះឡើយ។[4] ធនធានទាំងនេះអាចរួមបញ្ចូលដូចជា ទូកល្បាត សាំង ថវិការ ចាំបាច់ដើម្បីដើរល្បាត។

យោងតាមទិនន្ន័យបទល្មើសជលផលតំបន់ឆ្នេរនៅក្នុងឆ្នាំ២០១៥ មានបទល្មើសចំនួន ៦៤ ករណី ហើយនៅខែកក្កដា ឆ្នាំ ២០១៧ មាន៤១ ករណី (ទិន្នន័យសម្រាប់ឆ្នាំ២០១៦មិនអាចរកបាន)។[16] បទល្មើសភាគ

ច្រើនប្រព្រឹត្តឡើងដោយទូកនេសាទបរទេស[17, 18] ដែលបានបំផ្លាញត្រី ដោយការប្រើជាតិពុល ប្រេងសាំង គ្រាប់បែក គ្រឿងផ្ទុះ និងឧបករណ៍នេសាទខុសច្បាប់។ [18]

ជម្លោះជលផលអាចកើតមានក្នុងសហគមន៍នេសាទ ឬរវាងសហគមន៍នេសាទ។ ទោះជាយ៉ាងណាក៏ដោយ ព័ត៌មានស្តីពីជម្លោះជលផល និងដំណោះស្រាយជលផលមិនអាចរកបាននោះទេ។ សហគមន៍នេសាទសម្រុះសម្រួលនូវជម្លោះដែលកើតមាននៅក្នុងសហគមន៍របស់ពួកគេ។ ក្នុងករណីដែលជម្លោះមិនអាចដោះស្រាយបាន ជម្លោះនោះត្រូវបញ្ជូនទៅកាន់អាជ្ញាធររដ្ឋបាលជលផល ដោយការចូលរួមពីសំណាក់អាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរមានសមត្ថកិច្ចប្រសិនជាចាំបាច់។ ជម្លោះត្រូវបញ្ជូនទៅតុលាការ បើសិនរដ្ឋបាលជលផលនៅតែមិនអាចដោះស្រាយបាន។[19]

**ក្រាហ្វិកទី២៖ ទិន្នផលសមុទ្រ(២០០០-២០១៥)**




*ប្រភព៖ របាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

ការសិក្សាមួយចំនួនបានរកឃើញស្រដៀងគ្នាថាបរិមាណនៃផលចាប់ត្រីសមុទ្រមានការថយចុះ ដោយសារ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ការប្រើឧបករណ៍នេសាទល្មើសច្បាប់មួយចំនួន ការបូមខ្សាច់ និងកំនើនអ្នកនេសាទ ព្រមទាំងការបំផ្លិចបំផ្លាញព្រៃកោងកាង ស្មៅសមុទ្រ និងផ្កាថ្មដោយឧស្សាហកម្មធំៗជាដើម។[20, 21, 22] ក្រាហ្វិកទី២ខាងលើបង្ហាញថា ទិន្នផលសមុទ្រថ្នាក់ជាតិបានកើនឡើងជាបន្តបន្ទាប់។ យោងតាមទិន្នន័យឃុំ សង្កាត់ ចំនួនទូកនេសាទបានថយចុះ ហើយចំនួនអ្នកនេសាទមិនមានការប្រែប្រួលឡើយ។ ប្រសិនបើនេះជាការពិត ទិន្នន័យនេះអាចត្រូវបានសន្និដ្ឋានថាសកម្មភាពនេសាទខ្នាតមធ្យម និងខ្នាតធំ ប្រហែលជាបានរួមចំណែកដល់ការធ្លាក់ចុះនូវផលស្តុកត្រីសម្រាប់ប្រជានេសាទលក្ខណៈគ្រួសារ។

**តារាងទី៣ ៖ ចំណូលពីការនេសាទ( សមាជិកសហគមន៍នេសាទ ឆ្នាំ ២០១៥ -២០១៦)**

| **រដូវ** | **ប្រាក់ចំណូលនេសាទតាមរដូវ (ដុល្លារ)** | |
|---|---|---|
| | **អប្បរមា** | **អតិប្បរមា** |
| រដូវវស្សា | ៥៨៩ | ៩៣៦ |
| រដូវប្រាំង | ៩២៣ | ១៤៣៣ |

*ប្រភព៖ ការរៀបចំសហគមន៍នេសាទនៅប្រទេសកម្ពុជា[4]*

ចំណូលរបស់សមាជិកសហគមន៍នេសាទប្រែប្រួលទៅតាមរដូវប្រាំង និងរដូវវស្សា ព្រមទាំងតាមចំនួនសមាជិកផងដែរ។ ដូចដែលបានបង្ហាញនៅក្នុងតារាងទី៣ អ្នកនេសាទរកប្រាក់ចំណូលបានតិចតួច ហើយតែងតែមានគ្រោះថ្នាក់ក្នុងការនេសាទផងដែរក្នុងអំឡុងរដូវវស្សា។[4, 23] អ្នកនេសាទក្រីក្រ ដែលគ្មានជម្រើសមុខរបរផ្សេងទៀត ប្រហែលជាមានការលំបាកក្នុងការរស់នៅ ហើយប្រសិនបើការនេសាទត្រីថយចុះ ក្នុងចំណោមអ្នកនេសាទក្នុងមូលដ្ឋាន ការនេសាទតែមួយមុខប្រហែលមិនមែនជាជម្រើសប្រកបដោយចិរភាពក្នុងការទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគេនោះទេ។

គណៈកម្មាធិការគ្រប់គ្រងសហគមន៍នេសាទក៏ជួបប្រទះនូវបញ្ហាប្រឈមដូចជា កង្វះមូលនិធិ ចំណេះដឹង និងភាពជាអ្នកដឹកនាំនៅមានកម្រិត ការចូលរួមពីសមាជិកនៅតិចតួច កង្វះខាតនៃការគាំទ្រសម្រាប់ក្រុមល្បាត ការគាំទ្រពីអង្គការពាក់ព័ន្ធនៅមិនទាន់គ្រប់គ្រាន់នៅឡើយ ព្រមទាំងមានចំនួនប្រជាជនច្រើនពេកបានចូលរួមក្នុងសកម្មភាពនេសាទ។[4]

## ៤. គោលនយោបាយដែលមានស្រាប់ទាក់ទងនឹងសហគមន៍នេសាទសមុទ្រ

កំណែទម្រង់ជលផលដែលមានពីរដំណាក់កាលនៅកម្ពុជាបានចាប់ផ្តើមនៅឆ្នាំ២០០០ ដែលឈានទៅដល់ការលុបឡូតិ៍នេសាទមួយចំនួននៅដំណាក់កាលទីមួយ និងការលុបឡូតិ៍នេសាទដែលនៅសេសសល់ទាំងអស់នៅក្នុងកំណែទម្រង់ជលផលដំណាក់កាលទីពីរ។ កំណែទម្រង់ជលផលបានផ្តល់សិទ្ធិអំណាចដល់សហគមន៍មូលដ្ឋាន ទាំងសហគមន៍នេសាទទឹកសាប និងសមុទ្រ ព្រមទាំងផ្តល់សិទ្ធិដល់ពួកគេ ក្នុងការរៀបចំបង្កើតសហគមន៍នេសាទ គ្រប់គ្រងដែននេសាទរបស់ខ្លួន តំបន់អភិរក្ស និងចូលរួមក្នុងការដោះស្រាយជម្លោះ ចូលរួមក្នុងការប្រយុទ្ធប្រឆាំងនឹងការនេសាទខុសច្បាប់ជាដើម។[4] ខាងក្រោមនេះគឺជាអត្ថន័យសង្ខេបនៃគោលនយោបាយ ជលផលទាក់ទងនឹងការអភិវឌ្ឍសហគមន៍នេសាទ។

## *សេចក្តីថ្លែងការណ៍គោលនយោបាយ*

ទស្សនៈវិស័យសម្រាប់វិស័យជលផលគឺ “ការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍធនធានជលផលប្រកបដោយនិរន្តភាពដើម្បីរួមចំណែកដល់ការធានាសន្តិសុខស្បៀង និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនិងភាពរុងរឿងរបស់ប្រទេស”។ ការគ្រប់គ្រងសហគមន៍នេសាទ និងការនេសាទលក្ខណៈគ្រួសារ គឺជាសសរស្តម្ភមួយ នៃគោលនយោបាយវិស័យជលផល ដែលមានគោលបំណងបង្កើតសហគមន៍នេសាទ ជាមួយនឹងការគាំទ្រសម្រាប់ធានាជីវភាពរស់នៅប្រកបដោយចិរភាពដល់អ្នកនេសាទទាំងក្នុងលក្ខខណ្ឌសេដ្ឋកិច្ចសង្គម និងអាហារូបត្ថម្ភ ។ [24, 25]

## *កិច្ចខិតខំប្រឹងប្រែងដើម្បីជួយអភិវឌ្ឍសហគមន៍នេសាទ*

មានឯកសារយុទ្ធសាស្ត្រមួយចំនួនទាក់ទងនឹងសហគមន៍នេសាទដូចជា ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់ជលផលឆ្នាំ ២០១០-២០១៩ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៤-២០១៨។ រដ្ឋបាលជលផល (FiA) ដែលជាតួអង្គសំខាន់នៅក្នុងវិស័យជលផល មានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជលផលរយៈពេល៣ឆ្នាំ និងផែនការការងារប្រចាំឆ្នាំរបស់ខ្លួន។[5, 26] ដើម្បីសម្រេចបាននូវទស្សនៈវិស័យ ផ្នែកមួយនៃកិច្ចខិតខំរបស់រដ្ឋាភិបាល គឺជម្រុញឲ្យសហគមន៍ រៀបចំបង្កើត និងជួយអភិវឌ្ឍសហគមន៍នេសាទ។ ជារួម គោលនយោបាយវិស័យជលផល មានគោលបំណង បង្កើនការការពារ និងអភិរក្សធនធានជលផលតាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីជលផល លុបបំបាត់បទល្មើសនេសាទគ្រប់រូបភាព ពង្រឹងសមត្ថភាពគ្រប់គ្រងសហគមន៍នេសាទ និងជម្រុញការអភិវឌ្ឍវារីវប្បកម្ម ដើម្បីធានាឲ្យបាននូវចិរភាពធនធានជលផលព្រមទាំងកែលម្អគុណភាព និងសុវត្ថិភាពផលិតផលជលផលសម្រាប់ការប្រើប្រាស់ក្នុងស្រុក និងសម្រាប់ការនាំចេញ។

## *សមិទ្ធិផលសង្ខេប*

ក្រៅពីជោគជ័យទាក់ទងនឹងការអភិវឌ្ឍគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ និងការបង្កើតសហគមន៍នេសាទ ការស្រាវជ្រាវមួយបានអះអាងថាគោលបំណងផ្សេងទៀតនៃកំណែទម្រង់ជលផលពាក់ព័ន្ធដល់ការលើកកម្ពស់នៃការទទួលបានស្បៀងអាហារ និងជីវភាពរស់នៅត្រូវបានសម្រេច។[4] សមាជិកសហគមន៍នេសាទ អាចធ្វើការនេសាទបានសម្រាប់បរិភោគ និងអាចរកប្រាក់ចំណូល ដែលជាកត្តាយ៉ាងសំខាន់ក្នុងការលើកតម្កើងជីវភាពរស់នៅរបស់ពួកគេ។ អត្ថប្រយោជន៍សង្គមក៏ត្រូវបានរាយការណ៍ផងដែរ ដោយរួមទាំងការជឿទុកចិត្តកាន់តែច្រើននៅក្នុងសហគមន៍នេសាទ ការលើកកម្ពស់ការយល់ដឹង និងការឲ្យតម្លៃខ្ពស់លើការអភិរក្ស និងការប៉ង់ប្រាថ្នាកសាងអនាគតល្អប្រសើរមួយ ។[4]

## ៥. ការដោះស្រាយនូវបញ្ហាប្រឈមខាងលើ

### *កិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ*

ភាពក្រីក្រនៅក្នុងប្រទេសកម្ពុជាបន្តធ្លាក់ចុះ ហើយការបង្កើតមុខរបរកចិញ្ចឹមជីវិតថ្មីៗ បានដើរតួរនាទីក្នុងការកាត់បន្ថយភាពក្រីក្រផងដែរ។[27] ប្រាក់ចំណូលដែលមិនមែនជាប្រាក់ឈ្នួលកសិកម្មបានរួមចំណែកច្រើនជាងមួយភាគបីនៃចំណូលរបស់សហគមន៍នេសាទនៅតាមជនបទ។[27] នេះបង្ហាញថាកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការអនុវត្តផែនការអភិវឌ្ឍន៍នៅលើគ្រប់វិស័យកំពុងជួយកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទរួមទាំងក្នុងចំនោមសហគមន៍នេសាទ។ ជាពិសេស នៅតាមតំបន់ឆ្នេរ ផ្នែកមួយចំនួនដូចជា ការអភិវឌ្ឍតំបន់ឧស្សាហកម្ម(រួមទាំងការកែច្នៃផលិតផលសមុទ្រ) ការអប់រំ ទេសចរណ៍ ការអភិវឌ្ឍកសិកម្ម កំពង់ផែ គួរតែ ផ្តល់ជាអាទិភាព។ បន្ថែមលើការអនុវត្តន៍គោលនយោបាយវិស័យជលផល កត្តានេះនឹងពន្លឿននូវការធ្វើពពិធកម្មជីវភាពរបស់សហគមន៍នេសាទ។

ការសិក្សាមួយដោយអង្គការ អភិវឌ្ឍឧស្សាហកម្មនៃសហប្រជាជាតិ(UNIDO) សម្រាប់រាជរដ្ឋាភិបាលកម្ពុជាបានលើកឡើងថាប្រទេសកម្ពុជាគួរតែបង្កើនប្រសិទ្ធភាពលើវិស័យជលផលសមុទ្រដើម្បីឲ្យផលិតផលសមុទ្រកម្ពុជាអាចមានលទ្ធភាពទទួលបានការគាំទ្រពី ទីផ្សារក្នុងស្រុក និងក្រៅស្រុក។ ទីផ្សារកាន់តែច្រើនសម្រាប់ផលិតផលជលផលនឹងនាំឲ្យមានតម្រូវការកាន់តែច្រើនពីសហគមន៍នេសាទ។ របាយការណ៍នេះក៏បានលើកឡើងផងដែរនូវការបង្កើតហេដ្ឋារចនាសម្ព័ន្ធតាមរយៈខ្សែរសង្វាក់ផលិតកម្ម ដូចជាកន្លែងចូលចត រោងចក្រទឹកកក កន្លែងស្តុកផលិតផលត្រីដែលមានសីតណ្ហភាពត្រជាក់ ជាដើម ការពង្រឹងក្របខ័ណ្ឌច្បាប់សម្រាប់សុវត្ថិភាពចំណីអាហារ លើកកម្ពស់គុណភាពផលិតផល និងការធ្វើពពិធកម្មជីវភាពជាដើម ។ [28]

### *កិច្ចខិតខំប្រឹងប្រែងថ្នាក់មូលដ្ឋាន (រដ្ឋបាលជលផល)*

រដ្ឋបាលជលផល និងអង្គការមិនរកប្រាក់ចំណេញដែលពាក់ព័ន្ធបានគាំទ្រសហគមន៍នេសាទក្នុងការបង្កើតមុខរបរចិញ្ចឹមជីវិតផ្សេងៗ តាមរយៈការបង្កើតក្រុមសន្សំប្រាក់ ក្រុមកែច្នៃត្រី ក្រុមកែច្នៃបង្គារ ធនាគារក្តាម និងវគ្គ-បណ្តុះបណ្តាលស្តីពីការចិញ្ចឹមសត្វ និងការកែច្នៃផលិតផលត្រីទៅជាវត្ថុអនុស្សាវរីយ៍។ [6, 29] រដ្ឋបាលជលផលមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលបានធ្វើការងារពាក់ព័ន្ធដ៏ទៃទៀតដូចជា ការដាំព្រៃកោងកាង និងព្រៃឈើ ការអភិរក្សវារីរុក្ខជាតិ ព្រៃកោងកាង និងព្រៃលិចទឹក។ រដ្ឋបាលជលផលបានធ្វើការផងដែរដើម្បីប្រយុទ្ធប្រឆាំងសកម្មភាពនេសាទខុសច្បាប់ និងគាំទ្ររួមគ្នាដល់ក្រុមល្បាតសហគមន៍នេសាទ។ លើសពីនេះទៅទៀត ពួកគេបានជួយដើម្បីលើកកម្ពស់សមត្ថភាពគ្រប់គ្រងរបស់សហគមន៍នេសាទ ភាពធន់របស់ពួកគេនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងសមត្ថភាពរបស់ពួកគេដើម្បីការគ្រប់គ្រងធនធានរបស់ពួកគេ។

ដើម្បីសម្រេចបានតាមយុទ្ធនាការរបស់ក្រសួងក្នុងការជម្រុញឲ្យមាន«ឃុំមួយសហគមន៍ស្រះជម្រកត្រីមួយ» អធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ និងខណ្ឌរដ្ឋបាលជលផលតំបន់ឆ្នេរ ព្រមទាំងអង្គការដៃគូរ ប្រជាជនមូល

ដ្ឋាន និងអាជ្ញាធរមូលដ្ឋានបានបង្កើតជាសហគមន៍ស្រះជម្រកត្រី និងប្រព័ន្ធគ្រប់គ្រងសម្រាប់សហគមន៍នីមួយៗ។ ពួកគេក៏បានបង្កើតនូវយុទ្ធនាការជាសាធារណៈស្តីពីការអភិរក្សផងដែរ។[6]

រដ្ឋបាលជលផលក៏បានអនុវត្តសកម្មភាពអភិវឌ្ឍន៍ដទៃទៀតជួយដល់សហគមន៍នេសាទដោយប្រយោលផងដែរ។ សកម្មភាពទាំងនោះរួមមានការបង្កើតដែនជម្រកសុវត្ថិភាពសមុទ្រ តំបន់អភិរក្ស(៤០ តំបន់) តំបន់ការពារ(៤ តំបន់) និងការលែងកូនត្រី។

### *កិច្ចខិតខំប្រឹងប្រែងថ្នាក់មូលដ្ឋាន (ក្រុមប្រឹក្សាឃុំ)*

ក្រុមប្រឹក្សាឃុំរួមជាមួយរដ្ឋបាលជលផលមូលដ្ឋាន តើតួរង៏សំខាន់ក្នុងការជួយបង្កើតសហគមន៍នេសាទ និងក្នុងការលប់បំបាត់សកម្មភាពនេសាទខុសច្បាប់ និងការដោះស្រាយជម្លោះ។ សហគមន៍នេសាទអាចបញ្ចូលផែនការ និងតម្រូវការរបស់ខ្លួនទៅក្នុងផែនការអភិវឌ្ឍ និងផែនការវិនិយោគរបស់ក្រុមប្រឹក្សាឃុំ។ ការសិក្សាមួយក៏បាននែនាំផងដែរថា សហគមន៍នេសាទអាចនឹងត្រូវផ្លាស់ប្តូរទៅជាអង្គការដែលធ្វើការផ្តោតលើការរកស៊ីចិញ្ចឹមជីវិត។[4]

កិច្ចខិតខំប្រឹងប្រែងទាំងនេះរួមចំណែកដើម្បីធ្វើឲ្យប្រសើរឡើងដល់ជីវភាពរស់នៅរបស់សហគមន៍នេសាទ។ ទី១ ការអភិរក្ស ការបង្កើតតំបន់ការពារ ការលែងកូនត្រី ទប់ស្កាត់ការនេសាទខុសច្បាប់ គឺជាសកម្មភាពដែលបានធានានូវនិរន្តរភាពធនធានធម្មជាតិផ្តល់ប្រយោជន៍ដល់សហគមន៍។ ទី២ ការបង្កើនខ្សែរសង្វាក់ផលិតកម្មក្នុងវិស័យជលផលនឹងកើនឡើងនូវតម្រូវការសម្រាប់ទិន្នផលសមុទ្រនៅក្នុងមូលដ្ឋាន។ ចុងក្រោយការអភិវឌ្ឍន៍នៅក្នុងវិស័យដ៏ទៃទៀត ជួយលើកកម្ពស់ក្នុងការបង្កើតនូវរបរកស៊ីចិញ្ចឹមជីវិតផ្សេងទៀតដែលនាំឲ្យជីវភាពរស់នៅមានភាពប្រសើរឡើង។

## ៦. សេចក្តីសន្និដ្ឋាន

ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិរៀបចំបង្កើតសហគមន៍នេសាទ ប្រើប្រាស់ គ្រប់គ្រង និងអភិរក្សធនធានជលផលមូលដ្ឋានរបស់ខ្លួន។ សហគមន៍នេសាទសមុទ្រសរុបចំនួន ៤០ ត្រូវបានបង្កើតឡើង នៅខេត្តជាប់មាត់សមុទ្រទាំង៤។ សហគមន៍នេសាទសមុទ្រទាំងនេះទទួលបានអត្ថប្រយោជន៍ពីគោលនយោបាយស្តីពីជលផល និងគោលនយោបាយអភិវឌ្ឍន៍តំបន់ឆ្នេរ។ សហគមន៍នេសាទសមុទ្រអាចមានសិទ្ធិប្រើប្រាស់ធនធានជលផល សមុទ្រសម្រាប់ទ្រទ្រង់ជីវភាព និងប្រាក់ចំណូល និងមានសកម្មភាពរកប្រាក់ចំណូលផ្សេងទៀត នៅក្នុងវិស័យកសិកម្ម អេកូទេសចរណ៍ និងសកម្មភាពកែច្នៃ។ល។

ដើម្បីជួយអភិវឌ្ឍសហគមន៍នេសាទសមុទ្រ រដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយវិស័យជលផលមួយចំនួនដូចជា ក្របខ័ណ្ឌផែនការយុទ្ធសាស្រ្តសម្រាប់វិស័យជលផល២០១០-២០១៩ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍវិស័យកសិកម្ម ២០១៤-២០១៨ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍរបស់រដ្ឋបាលជលផល ផែនការប្រចាំឆ្នាំរបស់រដ្ឋបាលជលផល។ល។ កំណែទម្រង់វិស័យជលផលសម្រាប់សហគមន៍នេសាទ ត្រូវបានគេចាត់ទុកថាជាការសម្រេចគោលបំណងនៃការកែលម្អជីវភាពសហគមន៍នេសាទ និងការកសាងទំនុកចិត្តនៅក្នុងសហគមន៍។ ទោះជាយ៉ាងណាក៏ដោយ សហគមន៍នេសាទសមុទ្រនៅតែមានការប្រឈមមួយចំនួនដូចជាធនធានត្រី

ថយចុះ ផលចាប់ត្រីថយចុះ ពុំសូវមានជម្រើសសកម្មភាពជីវភាពផ្សេងទៀតសម្រាប់សមាជិកសហគមន៍ដែលក្រីក្រ។ល។

រដ្ឋបាលជលផល គឺជាស្ថាប័នចម្បងដែលទទួលខុសត្រូវក្នុងការប្រយុទ្ធប្រឆាំងនឹងការនេសាទខុសច្បាប់។ ដូចគ្នាផងដែរ សហគមន៍នេសាទក៏មានតួនាទីក្នុងការឃោមល្បាត និងសហការណ៍ជាមួយរដ្ឋបាលជលផលមូលដ្ឋាន និងអាជ្ញាធរមូលដ្ឋានដើម្បីប្រយុទ្ធប្រឆាំងនឹងការនេសាទខុសច្បាប់។ សហគមន៍នេសាទសមុទ្របានអះអាងថាពួកគេខ្វះខាតធនធានក្នុងការធ្វើយុទ្ធនាការឃោមល្បាតរបស់ខ្លួន។ ទាក់ទងនឹងការអភិវឌ្ឍសហគមន៍នេសាទសមុទ្រ កិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍កម្រិតថ្នាក់ជាតិដែលនឹងជួយជម្រុញការធ្វើពពិធកម្មជីវភាពរបស់សហគមន៍នេសាទសមុទ្រ គួរបន្តអនុវត្តនៅក្នុងវិស័យមួយចំនួនដូចជា អប់រំ ទេសចរណ៍ និងកសិកម្ម។ លើសពីនេះទៀត កែលម្អខ្សែសង្វាក់តម្លៃនៅក្នុងវិស័យជលផល ក៏ជាជម្រើសល្អ ដើម្បីទទួលបានទីផ្សារក្នុងស្រុក និងទីផ្សារនាំចេញកាន់តែច្រើនឡើង។ ដូចគ្នាដែរ កិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍មូលដ្ឋាន គួរនៅបន្ត ដែលមានគោលដៅធ្វើឲ្យលើកកម្ពស់សកម្មភាពទ្រទ្រង់ជីវភាពរស់នៅផ្សេងៗទៀត លើកកម្ពស់ការអភិរក្សព្រៃកោងកាង និងព្រៃលិចទឹក បង្កើនផលស្តុកត្រី បង្កើនសមត្ថភាពគ្រប់គ្រងរបស់សហគមន៍នេសាទ គាំទ្រក្រុមឃាមល្បាត និងលើកកម្ពស់ភាពធន់នឹងការប្រែប្រួលអាកាសធាតុ។

## <u>ឯកសារយោង</u>


1. MAFF (2011). The Strategic Planning Framework for Fisheries: 201 - 2019 Cambodia. *In:* ADMINISTRATION, F. (ed.). Kingdom of Cambodia
2. MAFF (2016). MAFF annual report 2015-2016 Phnom Penh, Cambodia MAFF.
3. Sovannaroth, O. (2012 ). *Coastal and Marine Environment in Cambodia* Master URBAN MANAGEMENT Scholl of Public Administration
4. Kurien, J. (2017 ). Community Fisheries Organization of Cambodia: Sharing processes, results and lessons learned in the context of the implementation of the SSF Guidelines Rome: FAO.
5. Royal Government of Cambodia (2006). Law on Fisheries Cambodia
6. Fisheries Administration (2015). Result and Situation of Fisheries at Coastal Zones Phnom Penh.
7. John, K. (2017). *FAO Fisheries and Aquaculture Circular* Phnom Penh, FAO.
8. MAFF (2005). Royal Decree on the Establishment of Community Fisheries. Cambodia
9. MAFF (2007). Sub-decree on the management of community fisheries. Cambodia
10. Raza, R. A. & Uwe, S. (2011). Cambodia Costal Situation Analysis Gland, Switzerland: IUCN.
11. Gaworecki, M. (2016). Cambodia declares first-ever marine protected area. *online newspaper*, 24 June
12. Ghataure, G. *Closer look: Designing Cambodia's first large marine protected area* [Online]. Online: Fauna& Flora International Available: http://www.fauna-flora.org/closerlook/designing-cambodias-first-large-marine-protected-area/ [Accessed 20 August 2017].
13. Hamilton, M. (2012). Perceptions of fishermen towards marine protected areas in Cambodia and the Philippines. Bioscience Horizons.
14. Royal Government of Cambodia (2014 ). National Strategic Development Plan 2014-2018 Phnom Penh Royal Government of Cambodia
15. Ministry of Tourism (2016). Toursim Statistics Report Year 2016. Phnom Penh, Cambodia
16. ធឿន, ប. ញ. (២០១៧). ៧ខែដើមឆ្នាំ២០១៧ ក្រសួងកសិកម្មប្រមូលថវិកាបានពីវិស័យជលផលជាង៣០ម៉ឺនដុល្លារ. *Fresh News*, ១៩ សីហា.
17. Fisheries Action Coalition Team. *Evident-Based Illegal Fishing Activities Data Collection Report* [Online]. Phnom Penh, Cambodia: Fisheries Action Coalition Team ( FACT). Available: https://app.box.com/s/4e701gtt6574tyzc9dv9 [Accessed 09 August 2017].
18. Koh Rong Samloem Community Fishery (2011). Koh Rong Samloem Community Fishery
19. MAFF (2007). Prakas on the Guideline for Community Fisheries.
20. Marine Conservation Cambodia (2011). Koh Rong Samloem Community Fishery Cambodia Fisheries Administration.
21. Marschke, M., Lykhim, O. & Kim, N. (2014). Can Local Institutions Help Sustain Livelihoods in an Era of Fish Declines and Persistent Environmental Change? A Cambodian Case Study *Sustainability*.
22. UNIDO, FiA & MAFF. (2015). *Environmental Impacts Assessment of Marine Fisheries Related Activities in Cambodia* [Online]. Phnom Penh, Cambodia: United Nations Industrial Development Organization (UNIDO), Fisheries Administration (FiA), and MAFF. Available: http://www.moc.gov.kh/tradeswap/userfiles/Media/file/Projects/EIF/CEDEP%20II/Materials%20(Marine%20Fishery)/Environmental%20Impact%20Aseessment%20on%20marine%20fisheries%20activities.pdf [Accessed 21 August 2017].
23. Wirya, K. & Dyna, E. (2004). Seasonal Factors Affect Fisher's Livelihoods: A Case Study Cambodia

24. Royal Government of Cambodia (2014). National Strategic Development Plan 2014-2018. Phnom Penh: Royal Government of Cambodia.
25. Royal Government of Cambodia (2015). Statement of the Royal Government of Cambodia on the National Fisheries Sector Policy.
26. Fisheries Administration. (2007). *Planning* [Online]. Available: http://www.fia.gov.kh/khmer/index.php?page=plans [Accessed 24 August 2017].
27. World Bank Group (2017). Cambodia Economic Update April 2017: Staying Competitive through Improving Productivity. Phnom Penh, Camboida.
28. United Nations Industrial Development Organization (2015). Value Chain Assessment of Marine Fisheries Sector and Roadmap for Development Cambodia.
29. Chap, S., Touch, P. & Jean-Christophe, D. (2016). Fisheries Reforms and Right-Based Fisheries: Insights From Community Fisheries Across Cambodia. Phnom Penh.